**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ.៧២៨......សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការបង្កើតក្រុមការងារចម្រុះ ដើម្បីចុះត្រួតពិនិត្យភាពច្បាស់លាស់បិទតែមប្រើអាករប្រភេទថ្មីសម្រាប់បារី

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៤៨០ សហវ.ប្រក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការប្រើប្រាស់តែមប្រើអាករសម្រាប់បង់អាករពិសេសលើផលិតផលបារី

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

-បានឃើញសារាចរណែនាំលេខ ០១៥ សហវ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការអនុវត្តការប្រើប្រាស់តែមប្រើអាករប្រភេទថ្មីសម្រាប់បង់អាករពិសេសលើផលិតផលបារី

-បានឃើញសេចក្តីជូនដំណឹងលេខ ០០១ សហវ.អពដ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការចុះត្រួតពិនិត្យការអនុវត្តកាតព្វកិច្ចបិទតែមប្រើអាករប្រភេទថ្មីសម្រាប់បារីចំពោះម្ចាស់សហគ្រាសផលិតបារីក្នុងស្រុក បារីនាំចូល អ្នកលក់ និងអ្នកចែកចាយបារីក្នុងស្រុកទាំងអស់

-យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.**

បង្កើតក្រុមការងារចម្រុះរវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| ១- លោក **ហេង ណារិទ្ធ** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ<br>នៃអគ្គនាយកដ្ឋានពន្ធដារ | សហប្រធាន |
| ២- លោក **អន ស៊ីនួន** | អនុប្រធាននាយកដ្ឋានរដ្ឋាករ<br>នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សហប្រធាន |
| ៣- លោក **ឡៃ សុខឡេង** | មន្ត្រីការិយាល័យគ្រប់គ្រងអាករពិសេស<br>នៃអគ្គនាយកដ្ឋានពន្ធដារ | លេខាធិការ |
| ៤- លោក **ញ៉ែម សន** | ភ្នាក់ងារគយនិងរដ្ឋាករ<br>នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | លេខាធិការ |

**ប្រការ ២.**

១-សហប្រធាននៃក្រុមការងារនេះ ត្រូវដឹកនាំក្រុមការងារចុះត្រួតពិនិត្យកាតព្វកិច្ចបិទតែមប្រើអាករប្រភេទថ្មីសម្រាប់បារី។ ក្នុងករណីសហប្រធានអវត្តមានដោយប្រការណាមួយ សហប្រធាននោះអាចចាត់តាំងតំណាងមួយរូបក្នុងក្រុមការងារដើម្បីដឹកនាំក្រុមការងារចម្រុះនេះ។

២-សហប្រធានត្រូវធ្វើការបូកសរុប និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការចុះត្រួតពិនិត្យជូនអគ្គនាយកដ្ឋានទាំងពីរដើម្បីសរុបលទ្ធផលជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ ៣.**

បង្កើតក្រុមត្រួតពិនិត្យចម្រុះទី១ រវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| ១- លោក **ខូច ម៉េងថៃ** | ប្រធានការិយាល័យគ្រប់គ្រងអាករពិសេស | សហប្រធាន |
| ២- លោក **ពេជ្រ ទិត** | អនុប្រធានការិយាល័យនៃសាខាគយនិងរដ្ឋាកររាជធានីភ្នំពេញ | សហប្រធាន |
| ៣- លោក **ស្រី សុជាតិ** | អនុប្រធានការិយាល័យគ្រប់គ្រងអាករពិសេស | អនុប្រធាន |
| ៤- លោក **ទ័ង់ ទឡ្ហៈ** | ភ្នាក់ងារគយនិងរដ្ឋាករនៃនាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើស | អនុប្រធាន |
| ៥- លោក **លី តារ៉ាណែល** | មន្ត្រីការិយាល័យគ្រប់គ្រងអាករពិសេស | សមាជិក |
| ៦- លោក **យុន សុគា** | មន្ត្រីការិយាល័យគ្រប់គ្រងអាករពិសេស | សមាជិក |

៧- លោកស្រី **កែវ ទីណែត** មន្ត្រីការិយាល័យគ្រប់គ្រងអាករពិសេស សមាជិក

៨- លោក **អាន រតនៈ** ភ្នាក់ងារគយនិងរដ្ឋាករនៃសាខាគយនិងរដ្ឋាកររាជធានីភ្នំពេញ សមាជិក

៩- លោក **ហេង ម៉ាលីដា** ភ្នាក់ងារគយនិងរដ្ឋាករនៃសាខាគយនិងរដ្ឋាកររាជធានីភ្នំពេញ សមាជិក

១០- លោក **ម៉ា សុណាត** ភ្នាក់ងារគយនិងរដ្ឋាករនៃនាយកដ្ឋានរដ្ឋាករ សមាជិក

**ប្រការ ៤.**

បង្កើតក្រុមត្រួតពិនិត្យចម្រុះទី២ រវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម÷

១- លោក **ម៉ៅ ធំ** ប្រធានការិយាល័យនៃនាយកដ្ឋានរដ្ឋាករ សហប្រធាន

២- លោក **សែ ណារ៉ុង** អនុប្រធានការិយាល័យគ្រប់គ្រងអាករពិសេស សហប្រធាន

៣- លោក **លាង ម៉ុង** អនុប្រធានការិយាល័យនៃសាខាគយនិងរដ្ឋាកររាជធានីភ្នំពេញ អនុប្រធាន

៤- លោកស្រី **ហ៊ាន រាសី** អនុប្រធានការិយាល័យគ្រប់គ្រងអាករពិសេស អនុប្រធាន

៥- លោក **ហ៊្វី សុជា** មន្ត្រីការិយាល័យគ្រប់គ្រងអាករពិសេស សមាជិក

៦- លោកស្រី **នាង សៀម** មន្ត្រីការិយាល័យគ្រប់គ្រងអាករពិសេស សមាជិក

៧- លោក **ឈុន ឆាស៊ីនខេល** មន្ត្រីការិយាល័យគ្រប់គ្រងអាករពិសេស សមាជិក

៨- លោក **ជ័យ សុខជា** ភ្នាក់ងារគយនិងរដ្ឋាករនៃសាខាគយនិងរដ្ឋាកររាជធានីភ្នំពេញ សមាជិក

៩- លោក **ណុប ឬទ្ធី** ភ្នាក់ងារគយនិងរដ្ឋាករនៃសាខាគយនិងរដ្ឋាកររាជធានីភ្នំពេញ សមាជិក

១០- កញ្ញា **ម៉ា ដូរី** ភ្នាក់ងារគយនិងរដ្ឋាករនៃសាខាគយនិងរដ្ឋាកររាជធានីភ្នំពេញ សមាជិក

**ប្រការ ៥.**

បង្កើតក្រុមត្រួតពិនិត្យចម្រុះទី៣ រវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម÷

១- លោក **ប៉ុក បូរក្សី** អនុប្រធានការិយាល័យគ្រប់គ្រងអាករពិសេស សហប្រធាន

២- លោក **ហេង សុភា** អនុប្រធានការិយាល័យនៃនាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើស សហប្រធាន

៣- លោក **គួយ រតនា** អនុប្រធានការិយាល័យគ្រប់គ្រងអាករពិសេស អនុប្រធាន

៤- លោក **ស៊ឹម សុវណ្ណារិទ្ធ** ភ្នាក់ងារគយនិងរដ្ឋាករនៃនាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើស អនុប្រធាន

៥- លោក **ស៊ី សេងអាន** មន្ត្រីការិយាល័យគ្រប់គ្រងអាករពិសេស សមាជិក

៦- លោក **គីម ចាន់** មន្ត្រីការិយាល័យគ្រប់គ្រងអាករពិសេស សមាជិក

៧- លោក **ហេង គីមហៀង** មន្ត្រីការិយាល័យគ្រប់គ្រងអាករពិសេស សមាជិក

៨- លោក **ឌុច ពាន់** មន្ត្រីការិយាល័យគ្រប់គ្រងអាករពិសេស សមាជិក

៩- លោក **ឌី សុរិទុធ** ភ្នាក់ងារគយនិងរដ្ឋាករនៃសាខាគយនិងរដ្ឋាកររាជធានីភ្នំពេញ សមាជិក

១០- លោក **ស្រី ស៊ីនឿន** ភ្នាក់ងារគយនិងរដ្ឋាករនៃសាខាគយនិងរដ្ឋាកររាជធានីភ្នំពេញ សមាជិក

